**គណៈកម្មាធិការរៀបចំ**
**Organizing Committee**

ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៣

# វេទិកាពិភាក្សាកម្មវិធីនយោបាយនៃគណបក្សនយោបាយនៅមុនពេលបោះឆ្នោត ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខ

ការបោះឆ្នោតជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ គឺជាព្រឹត្តិការណ៍មួយយ៉ាងសំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ការបោះឆ្នោតនេះ នឹងធ្វើឲ្យមានការតាមដានចំណាប់អារម្មណ៍អំពីកម្មវិធីនយោបាយនៃគណបក្សនយោបាយនិមួយៗ និងអំពីការអនុវត្តន៍គោលនយោបាយទាំងនោះពីសំណាក់ប្រជាពលរដ្ឋ និងប្រពន្ធ័ផ្សព្វផ្សាយ។

អង្គការសង្គមស៊ីវិលសំខាន់ៗមួយចំនួន នឹងប្រារព្ធធ្វើ «**វេទិកាពិភាក្សាកម្មវិធីនយោបាយនៃគណបក្សនយោបាយ**» នៅថ្ងៃព្រហស្បតិ៍ ទី០៦ ខែមិថុនា ឆ្នាំ២០១៣ នារាជធានីភ្នំពេញ ហើយគ្រប់គណបក្សនយោបាយសំខាន់ៗនឹងត្រូវអញ្ជើញឱ្យចូលរួម ដើម្បីបង្ហាញអំពីកម្មវិធីនយោបាយរបស់ខ្លួនទៅលើបញ្ហាសំខាន់ៗមួយចំនួន សម្រាប់ជាព័ត៌មានជូនសាធារណជន និងម្ចាស់ឆ្នោតអំពីកម្មវិធីគោលនយោបាយនៃគណបក្សនយោបាយរបស់ខ្លួន។ បញ្ហាដែលតំណាងគណបក្សនយោបាយត្រូវបានអញ្ជើញចូលរួម នឹងធ្វើការបកស្រាយនោះ មានពាក់ព័ន្ធនឹង កំណែទម្រង់ដីធ្លី សេដ្ឋកិច្ច បរិដ្ឋាន ព្រៃឈើ និងការផ្លាស់ប្តូរអាកាសធាតុ ការអភិវឌ្ឍន៍មនុស្ស និងសង្គម នីតិរដ្ឋ និងការទទួលបាននូវព័ត៌មាន។

វេទិកានេះសហការណ៍រៀបចំឡើងដោយ **NGO Forum on Cambodia, COMFREL, CCC, GADC, SILAKA, CCHR, DPA, VOD, CRRT, API, CPWP TI, and CHRAC**។ វេទិកាពិភាក្សាកម្មវិធីនយោបាយនេះ នឹងប្រារព្ធធ្វើនៅតាមខេត្តចំនួន២ផងដែរ គឺខេត្តកំពង់សោម និងមណ្ឌលគីរី។

យើងខ្ញុំសូមអំពាវនាវដល់គ្រប់ប្រធាននៃគណបក្សនយោបាយ ដែលត្រូវបានអញ្ជើញឲ្យនិយាយអំពីកម្មវិធីនយោបាយនៅក្នុងវេទិកានេះ បញ្ជូននូវបេក្ខជនសម្រាប់តំណែងជានាយករដ្ឋមន្ត្រី មកចូលរួមនៅក្នុងវេទិកានេះ ដែលនឹងមានការចូលរួមពីតំណាងសហគមន៍ចំនួន៣០០នាក់។

យើងខ្ញុំសូមស្វាគមន៍ និងអំពាវនាវដល់គ្រប់ប្រពន្ធ័ផ្សព្វផ្សាយទាំងអស់ ចូលរួមនៅក្នុងវេទិកានេះ ដើម្បីធ្វើការផ្សព្វផ្សាយអំពីកម្មវិធីនយោបាយដែលគណបក្សនយោបាយនិមួយៗបានលើកឡើង។

**ប្រធានបទ:** **កិច្ចពិភាក្សាកម្មវិធីនយោបាយ**

**ពេលវេលា:** **ថ្ងៃព្រហស្បតិ៍ ទី០៦ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង៧:៣០នាទី ដល់ម៉ោង៤:០០នាទី**

**ទីកន្លែង:** **អ៊ិមភីរៀលហ្គាដិនអូតែល**

អ្នកចូលរួម: តំណាងគណបក្សនយោបាយ តំណាងសហគមន៍ និងតំណាងអង្គការក្រៅរដ្ឋាភិបាល។


***សម្រាប់ព័ត៌មានបន្ថែម៖***

*លោក **សួន យុធ្យា** (ខុមហ្វ្រែល) ០៨៨ ៨១៤២៧៨៣*

*លោក **ឈិត សំអាត** (NGO Forum on Cambodia) ០១២៩២៨៥៨៥*